# បស្ចឹមប្រទេស និង លទ្ធិប្រជាធិបតេយ្យ

យើងដឹងថា នៅចំពោះមុខ **ដំណើរ រសាយ**[1] ភេរវកម្ម នៃ រដ្ឋអ៊ិស្លាម នៅក្នុងពិភពលោកបច្ចុប្បន្ន បស្ចឹមប្រទេស ជ្រើសរើស អាទិភាព ប្រឆាំងនឹង ដំណើររសាយនេះ ជាងការប្រឆាំងនឹងលទ្ធិផ្តាច់ការ។ ជម្រើសនេះ វាពិតជាមានយុត្តិកម្មរបស់វា បើយោងទៅលើ ភាពសហារ អកុសល នៃ រដ្ឋអ៊ិស្លាម។ កត្តាមួយទៀត គឺក្នុងនាម **នយោបាយប្រាកដនិយម**[2] នៃមហាអំណាច ដែលនិយម លទ្ធិប្រជាធិបតេយ្យសេរី បែរខ្នងដាក់ការតស៊ូ នៃក្រុមអ្នកប្រជាធិតេយ្យ ប្រឆាំងនឹង របបផ្តាច់ការ ដើម្បីរក្សាប្រយោជន៍ខ្លួន នៅក្នុងដំបន់ ឬ ក្នុងប្រទេសមួយ។ កត្តាមួយទៀតដែរ គឺ ការចុះអន់ថយ នៃ ឥទ្ធិពល អារ្យធម៌ បស្ចឹមប្រទេស នៅក្នុងពិភពលោកចាប់តាំងពីពាក់កណ្តាលសតវត្សទី២០មកម្លេះ។ កត្តាទាំងបីនេះឯង ជា ទេសភាពនយោបាយថ្មីនៃពិភពលោកបច្ចុប្បន្ន ដែលប្រជាពលរដ្ឋ រស់នៅក្នុង របបផ្តាច់ការ ឬ ក្នុងភាពក្រីក្រ ត្រូវទុកជាការពិតមួយ ដែលខ្លួនកំពុង រងគ្រោះ។ ស្គាល់ការពិតនេះ អាចជាជំនួយមួយដល់ប្រជាពលរដ្ឋ រងគ្រោះ សំរាប់យកមកពិចារណា ដើម្បីរកផ្លូវរំដោះខ្លួន ឲមានលំនាំត្រូវនឹងស្ថានការណ៍ថ្មី។

ពិតប្រាកដណាស់ អារ្យធម៌ បស្ចឹមប្រទេស នៅបន្តមាន **សហ័ស**[3] របស់ខ្លួន នៅក្នុងសតវត្សទី២១នេះ តែនៅត្រឹមវិស័យ **ការបង្កើតបច្ចេកទេសថ្មី**[4] និង យោធា ឯចំណែក ការត្រួតត្រា នៃធនធានធម្មជាតិ នៅក្នុងពិភពលោក វិញ ខ្លួនបាត់ ឯកាធិភាព ដែលធ្លាប់មាននៅក្នុងសតវត្សទី២០ **ជាកម្រៃចំពោះ**[5] ប្រទេស ឬ អារ្យធម៌ ដទៃទៀតៈ នាឆ្នាំ២០២០ ខាងមុខនេះ បស្ចឹមប្រទេសគ្រប់គ្រងទឹកដីនៅក្នុងពិភពលោក តែ ២៤% **តាង**[6] ៤៩% នៅក្នុងកំឡុងឆ្នាំ១៩២០ ; ១៥%ទៅ២០% នៃប្រជាពលរដ្ឋក្នុងពិភពលោក ; ៣០% នៃផលិតផលសេដ្ឋកិច្ច តាង ៧០% ពីអាតីតកាល។ តាម ការវិភាគ របស់លោក Samuel P. Huntington[7] អារ្យធម៌ស្ចឹមប្រទេសកំពុងមានការទង្គិច ជាមួយ អារ្យធម៌ដទៃទៀត នាំឲខ្លួន បាត់ឥទ្ធិពល របស់ខ្លួន នៅក្នុងពិភពលោក។ អានុភាព កាន់តែខ្លាំងឡើងៗ នៃ ប្រទេស មិនមែន ជាបស្ចឹមប្រទេស នៅក្នុងចរន្ត នវូបនីយកម្ម បណ្តាលឲមានកើត ឡើងវិញ នូវ វប្បធម៌ មិនមែន ជាវប្បធម៌បស្ចឹមប្រទេសនៅក្នុងពិភពលោក ដូចយ៉ាង ទំនាមទំលាប់ ភាសា ដែលបានចាក់ឫស រាប់សតវត្សរួចមកហើយនៅក្នុងសតិ នៃប្រជាពលរដ្ឋ ទាំងនោះ។

គេបែងចែក អានុភាព ពីរយ៉ាងៈ «**អានុភាព រឹង**» និង «**អានុភាព ស្រទន់**[8]»។ អានុភាព រឹង ស្ថិត នៅលើ អានុភាព យោធា និង សេដ្ឋកិច្ច ឯចំណែក អានុភាពស្រទន់ ស្ថិតនៅលើ

[1] ដំណើររសាយ= Prolifération។
[2] នយោបាយប្រាកដនិយម= Realpolitik ; នយោបាយការបរទេសដោយឈរលើកម្លាំង និង ប្រយោជន៍ជាតិជាធំ។
[3] សហ័ស= Puissance, force, hardiesse, រិទ្ធី។
[4] ការបង្កើតបច្ចេកទេសថ្មី= Innovation technologique។
[5] ជាកម្រៃចំពោះ= Au profit។
[6] តាង ឬ តាងយក= Au lieu de។
[7] Samuel P. Huntington : Le choc des civilisations – Edition Odile Jacob។
[8] អានុភាព រឹង= Puissance dure ; អានុភាព ស្រទន់= Puissance douce។

សមត្ថភាព នៃរដ្ឋខ្លាំងមួយ ដែលអាចយល់ដឹង ថា រដ្ឋខ្សោយ ឯទៀត ចង់បានអ្វីមួយ ពិត ដែលមាននៅក្នុង **វប្បធម៌** និង **មនោគមវិជ្ជា** ជាវិជ្ជមានរបស់ខ្លួន។ យើងដឹងថា បស្ចឹមប្រទេស កំពុងបាត់ ឥទ្ធិពលខ្លួន នៅក្នុងពិភាពលោក ដូច្នេះ អានុភាពរឹង របស់ខ្លួន ក៏ចុះខ្សោយតាមនោះដែរ តែ បស្ចឹមប្រទេស អាចនៅមាន អានុភាពស្រទន់ «វប្បធម៌ និង មនោគមវិជ្ជា» ដែលក្លាយជា គំរូសាកល វាអាច ទាក់ចិត្ត ឬ ធ្វើឲចាប់អារម្មណ៍ ដល់ប្រទេសឯទៀត នៅឡើយ ដោយសារមានជោគជ័យ ជាក់ច្បាស់ រហូតមកដល់បច្ចុប្បន្ននេះ។

## មនោគមវិជ្ជា

មនោគមវិជ្ជា គឺគ្មានអ្វី ក្រៅពី លទ្ធិប្រជាធិបតេយ្យសេរី នោះឯង។ Francis Fukuyama[9] នៅក្នុង សៀវភៅ របស់លោក សរសេរថា លទ្ធិប្រជាធិបតេយ្យសេរី ជា មនោគមវិជ្ជានយោបាយ មានជ័យជំនះដាច់គេ ក្នុងចំណោម មនោគមវិជ្ជាដទៃទៀត ដែលមាននៅក្នុងពិភពលោក ហើយ**ដំណាច់**[10] នៃមនោគមវិជ្ជា ម៉ាក្សនិយម គឺអាចចាត់ទុកបានជា ដំណាច់ នៃប្រវត្តិសាស្ត្រ ព្រោះ ដំណាច់ សហពភាព សូវៀត បានរំដោះ ប្រជាពលរដ្ឋជាច្រើន នៅទ្វីប អឺរ៉ុប ដែលបានរស់នៅក្នុងអំណាចកុម្មុយនិស្តក្រោយពីសង្គ្រាមលោកលើកទី២មក។ ដំណាច់នេះ ក៏ជាដំណាច់នៃ**អក្ខោសាន**[11] នៃពិភពលោក និង សង្គ្រាមត្រជាក់ រវាង លោក សេរី និង លោក កុម្មុយនិស្តដែលទុកឳកាសឲប្រទេសជាច្រើន រើសយក លទ្ធិប្រជាធិបតេយ្យសេរី ជាលទ្ធិដឹកនាំជាតិ។ តាំងពីបដិវត្តន៍បារាំង នាឆ្នាំ ១៧៨៩ មកដល់បច្ចុប្បន្នកាល លទ្ធិដែលទុកជា មហន្តរាយ ដល់មនុស្សជាតិ គឺលទ្ធិកុម្មុយនិស្ត។ ពី បដិវត្តន៍ នៅប្រទេស រុស្ស៊ី នាឆ្នាំ ១៩១៧ មកដល់ បដិវត្តន៍ ខ្មែរក្រហម នាឆ្នាំ ១៩៧៥ លទ្ធិដែលបានសម្លាប់មនុស្ស ដោយចំពោះ ឬ មិនចំពោះក្តី អស់ចំនួនប្រមាណ ១០០ លាននាក់ គឺ លទ្ធិកុម្មុយនិស្ត ហើយ របបដែលទុកជា អ្នកជើងឯង នៅក្នុងពិភពលោក គឺរបបខ្មែរក្រហម ដែលបណ្តាលឲជនជាតិខ្មែរស្លូតត្រង់ ស្លាប់ ជាង ២ លាននាក់ ដោយប្រៀបធៀបនឹងចំនួនប្រជាជនខ្មែរ ចំនួន ៧ លាននាក់ (២៩%)។ ផ្ទុយទៅវិញ លទ្ធិប្រជាធិបតេយ្យសេរី នាំមកជានិច្ច នូវភាពចំរើនលូតលាស់ គ្រប់វិស័យ ដល់ប្រទេស ណាដែលរើសយកលទ្ធិនេះមកធ្វើជារបបដឹកនាំជាតិ។ ឧទាហរណ៍ នៅក្នុង ដំបន់ អាស៊ី មានប្រទេសជាច្រើន ដូចយ៉ាង ប្រទេស ថៃ ម៉ាលេស៊ី ឥណ្ឌូណេស៊ី ជប៉ុន សិង្ហបូរី ឥណ្ឌា កូរ៉េខាងត្បូង ហ្វីលីពីន។ល។ ជ្រើសយកលទ្ធិប្រជាធិបតេយ្យសេរី មកអនុវត្តិ ពិតប្រាកដ នាំឲប្រទេសទាំងនោះ ស្គាល់នូវសេចក្តីចំរើនលូតលាស់ ហើយ ប្រជាពលរដ្ឋ រស់នៅក្នុងសន្តិភាព នៃនីតិរដ្ឋ មានសេរីភាពគ្រប់គ្រាន់ចូលធ្វើសកម្មភាព ក្នុងកិច្ចការសាធារណៈ ឬ នយោបាយ ដែលមានខ្លួនជាអធិបតី។ ប្រទេសខ្មែរក្រោយពីបានស្គាល់ មួយរយៈពេលខ្លី (១៩៤៧-១៩៥៦) ធ្លាក់ទៅក្នុង របបចម្លែកមួយ ដែលមានបុគ្គលសីហនុ ជាអ្នកដឹកនាំ នានាំប្រជាជាតិខ្មែរ ឲដើរទៅរកគ្រោះមរណៈ ដែលមានបក្សកុម្មុយនិស្ត ចិន/យួន ជាអ្នកបង្ករចលាចល។ អ្វីដែលអាចនឹងកើតមានឡើង ពីការយកភ្លើងជាល្បែង របស់ សីហនុ វាកើតមានពិតមែន នាឆ្នាំ ១៩៧០ គឺ ប្រទេសខ្មែរ មានឆេះភ្លើងសង្គ្រាម ដែលមាន បក្សកុម្មុយនិស្ត ចិន/យួន ជាអ្នកដុត ឲឆេះខ្លោច ធ្វើឲឈឺផ្សា ដល់ប្រជា

---

[9] Francis Fukuyama : La fin de l'histoire et le dernier homme – Edition Flammarion។
[10] ដំណាច់= Fin។
[11] អក្ខោសាន= បែកខ្ញែកគ្នា ; Polariser។

ជាតិខ្មែរ។ ស្ថានការណ៍ នៃប្រទេសខ្មែរបច្ចុប្បន្ន ដែលមានឋានៈ ជាប្រទេស រណប វៀតណាម គឺជាវិបាក នៃការបោះបង់ចោល នៃលទ្ធិប្រជាធិបតេយ្យសេរី នោះឯង។ យើងឃើញថា ខ្មែរ អ្នកស្រឡាញ់ សេរីភាពសព្វថ្ងៃ ធ្វើការទៀមទារ ឲអនុវត្តិ នូវកិច្ចព្រមព្រៀងសន្តិភាព ថ្ងៃទី ២៣ តុលា ឆ្នាំ ១៩៩១ គឺមានន័យថា ឲអនុវត្តិ លទ្ធិប្រជាធិបតេយ្យសេរី ដែលជាតម្លៃ នៃបស្ចឹមប្រទេស ក្លាយ ជាតម្លៃសាកល សំរាប់មនុស្សជាតិ ដែលបាន បង្ហាញ នូវភាពជាក់ស្តែង នៃភាពផ្តល់ នូវផលល្អ ដល់ប្រទេស និង ប្រជាពលរដ្ឋ ដែលបានរើសយក លទ្ធិនេះ មកអនុវត្តិច្បាស់លាស់។ តម្លៃនេះឯង ជាគុណូបការ របស់ បស្ចឹមប្រទេស ដែលបានបង្កើត លទ្ធិប្រជាធិបតេយ្យសេរី សំរាប់មនុស្សជាតិ ហើយជាលទ្ធិតែមួយគត់ ដែលធានា តាមផ្លូវច្បាប់ ដល់សិទ្ធិមនុស្ស និង សេរីភាព នៃប្រជាជន នៅក្នុងពិភពលោកសព្វថ្ងៃនេះ។ ប្រជាជន នៅក្នុងពិភពលោក នាឆ្នាំ ២០១៥ មានចំនួនប្រមាណ ៧,៣ កោដិ ក្នុងចំនួននេះ មាន ១១,៣% (២៥ នគរ) អនុវត្តិ លទ្ធិប្រជាធិបតេយ្យសេរី ជាសុក្រឹត្ត ; ៣៧,១%(៥៣ នគរ) អនុវត្ត លទ្ធិប្រជាធម បតេយ្យសេរី ជាអសុក្រឹត្ត, ១៤% (៣៧ នគរ) អនុវត្ត លទ្ធិប្រជាធិបតេយ្យសេរី កូនកាត់ ; ៣៧,៦% (៥២ នគរ) អនុវត្ត លទ្ធិផ្តាច់ការ[12]។ គេសង្កេតឃើញថាមានការវិវត្តន៍ ជាវិជ្ជមាន និង ជាការលើកទឹកចិត្ត នៃចំនួនមនុស្ស ៣៦,២៧% (៣២% នៅក្នុងឆ្នាំ១៩៧៣[13]) ក្នុងពិភពលោក រស់នៅក្នុងប្រទេសដែល គេអាចចាត់ទុកបានជា ប្រទេស «សេរី» ; ២៣,២៩% រស់នៅក្នុង របប សេរី-ពាក់កណ្តាល (២១% នៅក្នុងឆ្នាំ ១៩៧៣) ; រីឯ ៤០,៤៣% (៤៧% ក្នុងឆ្នាំ ១៩៧៣) រស់នៅក្នុងរបបផ្តាច់ការ។ គ្រប់ទីកន្លែង នៅក្នុងពិភពលោកសព្វថ្ងៃ លទ្ធិប្រជាធិបតេយ្យសេរី មានសភាពចម្រើន ទៅមុខជានិច្ច នៅពេលណា ប្រជាពលរដ្ឋហ៊ាន យក **វប្បធម៌ចាស់ណាស់**[14] របស់ខ្លួន មកពិចារណា ជាថ្មី ដោយខ្លួនឯង ដើម្បី សេរីភាព របស់ខ្លួន ដូច ប្រជាពលរដ្ឋ នៃបស្ចឹមប្រទេស ដែលគេបានធ្វើ តាំងពីសតវត្សទី១៨ មកម្លេះ ដើម្បី សេចក្តីចម្រើន នៃមនុស្សជាតិ។ ទង្វើ នេះ បង្កើតបាន ជាវប្បធម៌ ជាវិជ្ជាមានមួយ ដែលទុកជាគ្រឹះមួយសំរាប់ អនុវត្តិ លទ្ធិប្រជាធិបតេយ្យសេរី។

## វប្បធម៌

វប្បធម៌ នេះ គឺឈរលើ «**អភិចលនា នៃ វិវាទកម្ម**[15]» និង «**ការពិចារណា ជាថ្មី ជានិច្ច រកការពិតលើទំលាប់នៃការរស់នៅ**» នៅក្នុងសង្គម។ កត្តា ទាំងពីរនេះឯង ដែលធ្វើឲសង្គមរស់រវើក ជានិច្ចដែល ជាជីវចលនា សំរាប់ **ធ្វើបុនភាវកម្ម**[16] សង្គម អប់រំ សមាជិកសង្គម ឲមាន សម្បជញ្ញៈ អំពីតួនាទី របស់ខ្លួន ជា នាដករ សកម្ម នៃសង្គម។ នៅក្នុងសង្គម មានជីវចលនា ទុកមតិ នៃជនម្នាក់ៗ ជាបញ្ញា សំរាប់សង្គម តាងយក មតិក្រុម ឬ មតិវណ្ណៈ ទុកជា **ទិដ្ឋិ**[17] ជូនជាមតិផ្តាច់ការសំរាប់សង្គម ដែលជាការគំរាមកំហែងដល់ សេរីភាព បុគ្គលម្នាក់ៗ។ ការបោះបង់អានុភាពរឹង (អំណាច យោធា និង សេដ្ឋកិច្ច) របស់ បស្ចឹមប្រទេស រើសយកអានុភាពស្រទន់

[12] Les indicateurs et le classement sont ceux publiés par The Economist Intelligence Unit.
[13] Publié par Freedom House។
[14] វប្បធម៌ចាស់ណាស់= Culture séculaire។
[15] អភិចលនា នៃវិវាទកម្ម= Effervescence de contestation។
[16] បុនភាវកម្ម= កែជាថ្មី ; Régénérer។
[17] ទិដ្ឋិ=Dogme។

(វប្បធម៌) ជាផ្លូវថ្មី ដើម្បី រស់ក្នុង សុខដុម ជាមួយប្រទេសដទៃទៀត ក្នុងគតិនៃ សហប្រតិបត្តិការ រវាង ប្រជាជាតិ និង ប្រជាជាតិ នាំឲខ្លួន លែងមានលក្ខណៈជា ប្រទេសចក្រពត្តិ ផ្លាប់ ជិះជាន់ ប្រទេសទន់ខ្សោយ សំរាប់រក អត្ថប្រយោជន៏។

យើងដឹងថា លទ្ធិប្រជាធិបតេយ្យសេរី មិនមែនគ្រាន់តែជាគំរូ ដែលបស្ចឹមប្រទេសគេបានអនុវត្តិ ជាងមួយសតវត្ស ប្រកបដោយជោគជ័យនោះឡើយ គឺស្របជាមួយ កិច្ចអនុវត្តិនោះ ត្រូវចាំបាច់ អ្នកយកគំរូនេះជាយោង ត្រូវដូរ មានសិក: ខ្លួន ដែលទុកជាឧបសគ្គ សំរាប់ជោគជ័យនូវការផ្សាំ លទ្ធិប្រជាធិបតេយ្យសេរី ក្នុងសង្គម។ យើងអាចសន្និដ្ឋានបានថា លទ្ធិប្រជាធិបតេយ្យសេរី មិនគ្រាន់តែជា កិច្ចការច្បាប់តែប៉ុណ្ណោះទេ គឺជា កិច្ចការ វប្បធម៌ នោះដែរ។ ច្បាប់ និង វប្បធម៌ ត្រូវដើរ ឲស្របគ្នា ទើបអាចរកឃើញប្រសិទ្ធិភាព នៃលទ្ធិប្រជាធិបតេយ្យសេរីបាន។

## សេចក្តសន្និដ្ឋាន

បស្ចឹមប្រទេស ជញ្ជក់ប្រយោជន៏ ពីប្រទេសទន់ខ្សោយ តាមរបបអាណានិគម ជាងមួយសតវត្ស ដោយប្រើ អានុភាពរឹង ជាមធ្យោបាយ តែសេចក្តីចម្រើន នៃលទ្ធិប្រជាធិបតេយ្យសេរី នេះឯង ជា **និយតករ**[18] នូវសីលធម៌ ហើយ សីលធម៌ ជាវប្បធម៌ នេះឯង ហាមឃាត់ ដោយខ្លួនឯង បស្ចឹមប្រទេស មិនឲបន្តនយោបាយជញ្ជក់ប្រយោជន៏ ព្រោះជានយោបាយ គ្មានច្រកចេញ គ្មានចំណេញ ទៅថ្ងៃមុខ នោះឡើយ។ ដំណាច់ របបអាណានិគម ក្នុងពាក់កណ្តាលសតវត្សទី២០ តាមផ្លូវហឹង្សា ឬ អហឹង្សាក្តី ទុកស្នាមជាវិជ្ជមាន នៅក្នុង អតីត ប្រទេស អាណានិគម នូវវប្បធម៌ នៃវឌ្ឍនភាព ដែលនាំឲមាន ការបេះបោរ នៃប្រជាជន រស់នៅក្រោមរបបអាណានិគម ឬ នៅក្រោមអានុភាពរឹង នៃបស្ចឹមប្រទេស ក្នុងសតវត្សទី២០។ បស្ចឹមប្រទេស ក្លាយជាសត្រូវផង ជាគំរូផង សំរាប់ប្រទេសដទៃទៀត។ ជា សត្រូវ គឺ ការតស៊ូ ដើម្បីឯករាជ្យ នៃអតីតប្រទេសអាណានិគម ; ជាគំរូ គឺ យកវិធី បស្ចឹមប្រទេស «**អភិចលនា នៃ វិវាទកម្ម**» និង «**ការពិចារណា ជាថ្មី ជានិច្ច រកការពិតលើទំលាប់នៃការរស់នៅ**» ជាមធ្យោបាយតស៊ូ។ កាលនោះ មាន ចលនា តស៊ូពីរៈ ចលនា សេរី យកលទ្ធិប្រជាធិបតេយ្យសេរី ជាគោលដៅជាទីបញ្ចប់ និង ចលនា កុម្មុយនិស្ត យក បដិវត្តន៏វណ្ណៈ ជាមធ្យោបាយ ដើម្បី បង្កើត សង្គមគ្មានវណ្ណៈ។ ការទុលមុខគ្នារវាង ចលនាតស៊ូទាំងពីរនេះ បង្កើត ជាសង្គ្រាមយោធាផង ដូចនៅក្នុងប្រទេសវៀតណាមជាអាទ៍ ជាសង្គ្រាមត្រជាក់ផង រវាង លោក សេរី និង លោក កុម្មុយនិស្ត តែនៅទីបញ្ចប់ អ្នកដែលបានឈ្នះ គឺ លទ្ធិប្រជាធិបតេយ្យសេរី។ ទុកជាឧទាហរណ៏ គឺ ការវិនាស នៃប្រព័ន្ធ សូរវៀត នៅទ្វិបអឺរ៉ុប ដែលជាការបញ្ជាក់ច្បាស់ នូវជោគជ័យជាស្ថាពរ នៃលទ្ធិប្រជាធិបតេយ្យសេរី លើ លទ្ធិកុម្មុយនិស្ត។ ជ័យជំនះនេះជាផលា នូវ ការខំប្រឹងប្រែង ជាអចិន្ត្រៃ នៃ បស្ចឹមប្រទេស ប្រឆាំងនឹង លទ្ធិកុម្មុយនិស្តនៅក្នុងពិភពលោក។ ការផ្ទេប្រហែស នៃ ការបន្តប្រឆាំងនឹង លទ្ធិកុម្មុយនិស្ត ក្នុងនាម នយោបាយប្រាកដនិយម និង អាទិភាព ប្រឆាំងនឹង ដំណើររសាយ នៃ រដ្ឋអ៊ិស្លាម ជា ការច្រឡំមួយរបស់ បស្ចឹមប្រទេស ព្រោះថាតម្លៃ បស្ចឹមប្រទេសគឺ ស្ថិតនៅលើ លទ្ធិប្រជាធិបតេយ្យសេរី និង វប្បធម៌ស្រទន់។ បើបស្ចឹមប្រទេស បន្ធូរ នូវ

[18] និយតករ= Régulateur។

ការប្រឆាំងនេះ គឺច្បាស់ជា នៅអានាគតកាល ដ៏ខ្លីមួយ ខ្លួននិងប្រឈមមុខនឹងរណសិរ្សបី ធំៗ រដ្ឋអ៊ីស្លាម រដ្ឋអំណាចផ្តាច់ការ និង ការវិលត្រឡប់មកវិញ នូវវិធីអនុវត្តិ កុម្មុយនិស្ត ដើម្បី បំផ្លាញ លទ្ធិប្រជាធិបតេយ្យសេរី។ ការព្យាយាម លើកដំកើង លទ្ធិប្រជាធិបតេយ្យសេរី នៅក្នុង ពិភពលោក ពីសំណាក់ បស្ចឹមប្រទេសជា រនាំង ទប់នឹង គ្រប់ប្រព័ន្ធណា ដែលអាចបំផ្លាញ លទ្ធិ សាកលនេះបាន។

ឧប សៅ សង្ហា

ថ្ងៃទី ១០ កុម្ភៈ ឆ្នាំ ២០១៥